PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត
Listening. Understanding. Delivering.

# ដំណោះស្រាយលើ
# ការការពារសមាជិកគ្រួសារ
# របស់អ្នកទាំងមូល



**PRU**ថែទាំ

# ហេតុអ្វីជាវ PRUថៃទាំ ?

ផ្ដល់ជូនអត្ថប្រយោជន៍

**100%**

នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

អត្ថប្រយោជន៍បន្ថែមគោល

**500%**

នៃទឹកប្រាក់ត្រូវបាន ធានារ៉ាប់រងក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរ

## អត្ថប្រយោជន៍បន្ថែមដែលអាចជ្រើសរើសថៃមរួមមាន៖

- អត្ថប្រយោជន៍បន្ថែម 500% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ
- អត្ថប្រយោជន៍បន្ថែម 100% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងករណីធ្វើរោគវិនិច្ឆ័យរកឃើញថាមាន ជំងឺមហារីកណាមួយនៃអត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ)
- អត្ថប្រយោជន៍បន្ថែម 50% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង សម្រាប់ផលវិបាកនៃការមានគភ៌
- អត្ថប្រយោជន៍បន្ថែម 10% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង សម្រាប់ការវះកាត់ស្ដារឡើងវិញ ឬការផ្សាំនៃស្បែក
- អត្ថប្រយោជន៍បន្ថែម 25% នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង សម្រាប់ផលវិបាកនៃជំងឺទឹកនោមផ្អែម

ងាយស្រួលក្នុង**ការជាវ និងទាមទារសំណង**

# កញ្ចប់ PRUថៃទាំ

| ប្រវត្តិរូបរបស់អតិថិជន | | | | | | |
|---|---|---|---|---|---|---|
| មនុស្សពេញវ័យ / កុមារ | | មនុស្សពេញវ័យ | | | | កុមារ |
| ភេទ | | ប្រុស | | ស្រី | | ទាំងពីរភេទ |
| ក្រុមមុខរបរ (*) | | 1 & 2 | 3 & 4 | 1 & 2 | 3 & 4 | ទាំងបួនក្រុម |
| ផលិតផលធានារ៉ាប់រង PRUថៃទាំ | | | | | | |
| ផលិតផល | ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ | ✓ | ✓ | ✓ | ✓ | ✓ |
| ផលិតផលធានារ៉ាប់រង PRUការពារជំងឺធ្ងន់ធ្ងរ | | | | | | |
| អត្ថប្រយោជន៍ដែលត្រូវធានាចាំបាច់ | ករណីជំងឺធ្ងន់ធ្ងរ (x500%) | ✓ | ✓ | ✓ | ✓ | ✓ |
| អត្ថប្រយោជន៍បន្ថែមដែលមិនចាំបាច់ធានាជាចាំបាច់ | ករណីជំងឺធ្ងន់ធ្ងរកើតឡើងលើកុមារ (x500%) | ✗ | ✗ | ✗ | ✗ | ✓ |
| | អត្ថប្រយោជន៍បន្ថែមលើជំងឺមហារីក (តាមភេទ) (x100%) | ✓ | ✓ | ✓ | ✓ | ✓ |
| | ផលវិបាកនៃជំងឺទឹកនោមផ្អែម (x25%) | ✓ | ✓ | ✓ | ✓ | ✓ |
| | ផលវិបាកនៃការមានគភ៌ (x50%) | ✗ | ✗ | ✓ | ✓ | ✗ |
| | ការវះកាត់ស្ដារឡើងវិញ ឬការផ្សាំនៃស្បែក (x10%) | ✓ | ✗ | ✓ | ✗ | ✗ |

## កំណត់សម្គាល់ (*)៖

ក្រុមមុខរបរ 1 និង 2 សំដៅដល់ការងារដែលមិនពាក់ព័ន្ធ ឬពាក់ព័ន្ធក្នុងកម្រិតតិចទៅនឹងការប្រើប្រាស់កម្លាំងកាយសម្បទា ហើយមិន ប្រឈម ឬ ប្រឈមមុខតិចតួចទៅនឹងគ្រោះថ្នាក់ចៃដន្យ ឬហានិភ័យដល់សុខភាព។ ក្រុមមុខរបរ 3 និង 4 សំដៅដល់ការងារ ដែលមានពាក់ព័ន្ធនឹងការប្រើកម្លាំងកាយសម្បទាជាមធ្យម ឬជាចម្បង ហើយអាចប្រឈមមុខទៅនឹងគ្រោះថ្នាក់ចៃដន្យ ឬ ហានិភ័យដល់សុខភាពកម្រិតមធ្យមឬកម្រិតខ្លាំង។

### 1. ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រង

ទទួលមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង នោះបណ្ណសន្យារ៉ាប់រង នឹងត្រូវបានបញ្ចប់បន្ទាប់ពីការផ្តល់សំណងលើករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

### 2. អតិថិជនអាចជារផលិតផល

ជាមួយទឹកប្រាក់ត្រូវបានធានារ៉ាប់រងចាប់ពី 1,000 ដុល្លារអាមេរិកទៅ 5,000 ដុល្លារអាមេរិកចំពោះអត្ថប្រយោជន៍លើករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងអាចធ្វើការជ្រើសរើសកញ្ចប់អត្ថប្រយោជន៍ទៅតាម តម្រូវការនិងប្រវត្តិរូបរបស់អតិថិជនដូចដែលបានបង្ហាញខាងលើ។ ទឹកប្រាក់ត្រូវបានធានារ៉ាប់រងនៃអត្ថប្រយោជន៍បន្ថែមនីមួយៗត្រូវបានផ្តល់ជូនដោយគិតជាភាគរយនៃទឹកប្រាក់ត្រូវបានធានារ៉ាប់រងរបស់អត្ថប្រយោជន៍លើករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

### 3. បុព្វលាភធានារ៉ាប់រង

នឹងត្រូវប្រែប្រួលទៅតាមអាយុ ទឹកប្រាក់ត្រូវបានធានារ៉ាប់រង ភេទ និងអត្ថប្រយោជន៍ដែលបានជ្រើសរើស។

### 4. បណ្ណសន្យារ៉ាប់រងនេះមានរយៈពេលកំណត់ 5ឆ្នាំ

នឹងអាចបន្តសុពលភាពបណ្ណសន្យារ៉ាប់រងរៀងរាល់ 5ឆ្នាំម្តង ដែលនឹងអាស្រ័យ ទៅលើគោលការណ៍នៃការផ្តល់ជូនរបស់ក្រុមហ៊ុនលើផលិតផលធានារ៉ាប់រងនេះនៅពេលបន្តសុពលភាពបណ្ណសន្យារ៉ាប់រងនោះ។

# ករណីមិនធានា

ករណីមិនធានាសំខាន់ៗសម្រាប់ផលិតផលធានារ៉ាប់រង **PRU**ថៃទាំ និង **PRU**ការពារជំងឺធ្ងន់ធ្ងរ រួមមានតែមិនចំពោះ៖

1. ការធ្វើអត្តឃាត ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង
2. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ
3. ស្ថានភាព ឬជំងឺមានពីមុនស្រាប់
4. ជំងឺ ឬស្ថានភាពណាមួយដែលមានវត្តមាន ឬ ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញនៅក្នុងរយៈពេលរង់ចាំ
5. ស្ថិតក្រោមឥទ្ធិពលនៃការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង
6. ការធ្វើរោគវិនិច្ឆ័យរកឃើញជំងឺ ឬស្ថានភាពណាមួយដោយសភាពមិនប្រក្រតីពីកំណើត
7. ករណីមរណភាពក្នុងអំឡុងពេលរស់រានមានជីវិត 14ថ្ងៃ

ប្រសិនបើអត្ថប្រយោជន៍លើការវះកាត់ស្តារឡើងវិញ ឬការផ្សាំនៃស្បែក ត្រូវបានជ្រើសរើស នោះករណីមិនធានាខាងក្រោមនេះក៏នឹងត្រូវបានអនុវត្តបន្ថែមពីលើករណីមិនធានាខាងលើ៖

1. ការព្យាបាលសម្រាប់ជំងឺ  ឬរបួសបណ្តាលមកពីសកម្មភាព ឬ កីឡាដែលងាយមានគ្រោះថ្នាក់
2. ការចូលរួមសកម្មភាពបាតុកម្ម និងកូដកម្មទាក់ទងនឹងផ្នែកនយោបាយ កូដកម្ម ភេរវកម្ម ការរំលោភ ឬការប៉ុនប៉ងរំលោភច្បាប់ ការទប់ទល់ប្រឆាំងទៅនឹងការចាប់ ខ្លួនឬការដាក់ពន្ធនាគារណាមួយ
3. ផលវិបាកដែលកើតឡើងដោយសារការធ្លាក់នុយក្លេអ៊ែរ វិទ្យុសកម្ម សមាសភាពនុយក្លេអ៊ែរ សម្ភារៈឬកាកសំណល់នុយក្លេអ៊ែរ និង ហានិភ័យពាក់ព័ន្ធនឹងសង្គ្រាមផ្សេងៗទៀត។

**សម្គាល់៖** សម្រាប់ព័ត៌មានលម្អិតលើករណីមិនធានា និងរយៈពេលរង់ចាំ សូមអានបណ្ណសន្យារ៉ាប់រង។

PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

Listening. Understanding. Delivering.

# យើងចង់ជួយអ្នកស្វែងយល់បន្ថែមអំពីដំណោះស្រាយ ដែលសមស្របនឹងអ្នក និងគ្រួសាររបស់អ្នក។

## លោកអ្នកអាចទាក់ទងមកកាន់យើងខ្ញុំតាមរយៈ៖

- 023 964 222
- 1800 21 22 23 (ឥតគិតថ្លៃ)
- info@prudential.com.kh
- www.prudential.com.kh
- អគារវីត្រាស់ថាវរើរ៍ ជាន់ផ្ទាល់ដី, #២៤ ផ្លូវលេខ ១៦៩ (មហាវិថីឆេកូស្លូវាគី) សង្កាត់វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រលេខ ៤១៧

ពួកយើងត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយសំណួររបស់លោកអ្នក។

